ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សុន្ទរកថា
ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
ក្នុងសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៦
**ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦**

- *សូមគោរពគណៈអធិបតី*
- *ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា និងរាជធានី-ខេត្ត*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា និងរាជធានី-ខេត្ត*
- *អស់លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គរបស់យើងនាពេលនេះ*

តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្ស រីករាយយ៉ាងក្រៃលែង ដោយបានមកធ្វើជាអធិបតីក្នុងពិធីបើកសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៦ ដ៏មានសារៈសំខាន់ នាទីស្តីការគណៈរដ្ឋមន្ត្រីដ៏សែនមនោរម្យ បន្ទាប់ពីកិច្ចប្រជុំពេញអង្គ ដែលបានប្រព្រឹត្តទៅកាលពីម្សិលមិញ។ ក្នុងឱកាសដ៏ប្រពៃនេះ ជាថ្មីម្តង

ទៀត ខ្ញុំសូមសម្ដែងនូវអំណរ គុណចំពោះវត្តមានដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ លោក លោក ស្រី នាងកញ្ញា ចូលរួមធ្វើការ បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០១៧ ក្នុងការឆ្លើយ តបនឹងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជារបស់យើង ។

ក្នុងរយៈពេលមួយឆ្នាំនេះ យើងបានបំពេញភារកិច្ចយ៉ាងសកម្មរួមគ្នា ដើម្បីឈានទៅបញ្ចប់ការ ឆ្លងរាលដាលជំងឺអេដស៍ក្នុងដំណាក់កាលដែលស្ថានភាពជំនួយបរទេសធ្លាក់ចុះ។ នៅក្នុងរយៈពេលផ្ទេរ ដំណាក់កាលនេះ យើងទាំងអស់គ្នាចាប់ផ្តើមបំពេញតួនាទីក្នុងភាពជាម្ចាស់ ដោយប្ដេជ្ញារួបរួមគ្នាបញ្ចប់នូវ ការឆ្លងរីករាលដាលមេរោគអេដស៍នៅកម្ពុជាក្នុងឆ្នាំ២០២៥។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តលើ សេចក្ដីថ្លែងការណ៍នយោបាយស្ដីពីមេរោគ អេដស៍ និងជំងឺអេដស៍ ៖ ការបង្កើនល្បឿនវឌ្ឍនភាពដើម្បីសម្រេចក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និង ឈានទៅលុបបំបាត់ការរីករាលដាលមេរោគអេដស៍នៅមុនឆ្នាំ២០៣០។ នៅកម្ពុជា យើងប្ដេជ្ញាថានឹងលុប បំបាត់ការរីករាលដាលជំងឺអេដស៍នៅឆ្នាំ២០២៥។ ដូច្នេះ ក្នុងរយៈពេល៣ឆ្នាំខាងមុខ គឺនៅឆ្នាំ២០២០ យើងត្រូវសម្រេចឱ្យបាននូវគោលដៅ ៩០-៩០-៩០ ដែលជាដំណាក់កាលមុនការលុបបំបាត់។ ក្នុងនេះ មានន័យថា ៖ ១) ៩០%នៃមនុស្សទាំងអស់ដែលផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគ អេដស៍របស់ពួកគេ ២) ៩០%នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលបានធ្វើរោគវិនិច្ឆ័យ បានបន្តទទួល ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៣) ៩០%នៃមនុស្សទាំងអស់ដែល ទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍នឹងត្រូវឃើញថាបានកម្ចាត់មេរោគអេដស៍ពីក្នុង ឈាមរបស់ខ្លួន។

នៅក្នុងដំណាក់កាលលុបបំបាត់ ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៥ យើងត្រូវសម្រេចឱ្យបាននូវគោល ដៅ ៩៥-៩៥-៩៥ ក្នុងនោះ ៖ ១) ៩៥%នៃមនុស្សទាំងអស់ដែលផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាព ផ្ទុកមេរោគអេដស៍របស់ពួកគេ ២) ៩៥%នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលបានធ្វើរោគវិនិច្ឆ័យ បាន បន្តទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៣) ៩៥%នៃមនុស្សទាំង អស់ដែលទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ នឹងត្រូវឃើញថាបានកម្ចាត់មេរោគ អេដស៍ពីក្នុងឈាមរបស់ខ្លួន។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

តាមរយៈសេចក្ដីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០១៦ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្ដង ទៀតនូវកិច្ចការងារដែលយើងទាំងអស់គ្នាត្រូវសហការគ្នាធ្វើ ឱ្យសម្រេចក្នុងឆ្នាំ២០១៧ខាងមុខ ដើម្បី ឈានទៅបញ្ចប់ការចម្លងមេរោគអេដស៍ដូចខាងក្រោមនេះ ៖

១) យើងត្រូវបន្តកៀរគររកជំនួយបរទេស ដើម្បីឈានទៅបិទបញ្ចប់ការឆ្លងរីករាលដាលមេរោគអេដស៍

ជាស្ថាពរ។

២)ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ត្រូវរួមសហការគ្នាទប់ស្កាត់ការរីករាលដាល មេរោគអេដស៍ និងជំងឺអេដស៍ឱ្យមានប្រសិទ្ធភាព ភាពសក្តិសិទ្ធិ និងចីរភាព។

៣) ត្រូវពង្រឹងយន្តការត្រួតពិនិត្យ និងរៀបចំគោលការណ៍ណែនាំស្ដីពីការប្រុងប្រយ័ត្នជាសកលចំពោះ ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីកុំឱ្យករណីដូចនៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង កើតឡើងជាថ្មី។

៤)ត្រូវបន្តអនុវត្តកម្មវិធីជំរុញសកម្មខ្លាំងក្លាស្វែងរក និងថែទាំព្យាបាលករណីផ្ទុកមេរោគអេដស៍នៅ ទូទាំងប្រទេស។

៥) ត្រូវពង្រឹង និងជំរុញការអប់រំផ្សព្វផ្សាយផ្ដល់ចំណេះដឹងស្ដីពីការទប់ស្កាត់ការរីករាលដាលមេរោគ អេដស៍ និងជំងឺអេដស៍ឱ្យចំគោលដៅ និងមានប្រសិទ្ធភាព។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការរួមគ្នាបន្តអនុវត្តការងារឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ អាចឱ្យយើងលុបបំបាត់ការរីករាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥ នៅកម្ពុជាទៅតាម ការប្ដេជ្ញាចិត្ត។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជ័យមង្គលជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាង កញ្ញាសូមមានសុខភាពល្អ កម្លាំងមាំមួន ដើម្បីសម្រេចបាននូវវត្ថុបំណងនៃកិច្ចប្រជុំទៅតាមការរំពឹងទុក។

ខ្ញុំសូមប្រកាសបើក “សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៦” ចាប់ពីពេលនេះ តទៅ។

*សូមអរគុណ!*